# បេឡាជាតិរបបសន្តិសុខសង្គម

# National Social Security Fund

ប.ស.ស ឆ្នាំទី៦ ឆ្នាំ២០១៦ ព្រឹត្តិបត្រព័ត៌មាន

១៦









ធានាសន្តិសុខប្រាក់ចំណូល

រួមចំណែកកាត់បន្ថយភាពក្រីក្រ

លើកកំពស់ស្ថិរភាពសង្គម

## អ្នកមានជួយអ្នកក្រ

## អ្នកមានសុខភាពល្អ ជួយអ្នកឈឺ

Hotline 24h/7

សេវាសង្គ្រោះបន្ទាន់

១២៨៦

# មាតិកា

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម


១- រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម..................................................១

២- សិក្ខាសាលាផ្សព្វផ្សាយប្រកាសអន្តរក្រសួង ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព និងកិច្ចព្រមព្រាងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាលរវាង ប.ស.ស និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព..................................................២

២- ទស្សនៈកិច្ចសិក្សាផ្លូវការរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម នៅអង្គភាពសេវាកម្មសុខុមាលភាព និងជុសជុលគ្រោះថ្នាក់ការងារ នៃសាធារណៈរដ្ឋកូរ៉េ ...៤

៣- អបអរសាទរចំពោះបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលបានទទួលបណ្ណសរសើរ ស្តីពីកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ..................................................៥

៤- កិច្ចប្រជុំរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃប.ស.ស ..........................៦

៥- ពិធីចែកបណ្ណបើកបរដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅសាលាស្រុកបាទីខេត្តតាកែវ ..................................................................................៧

៧- កិច្ចប្រជុំផ្សព្វផ្សាយអំពីការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ នៅរោងចក្រ SABRINA (CAMBODIA) GARMENT MANUFACTURING CORP .......................៨

៨- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរដឹកកម្មករនៅរោងចក្រ GHUANG LI (CAMBODIA) GARMENT Co.,ltd ខេត្តស្វាយរៀង ..........................៩

៩- កម្មករ-កម្មការិនី ដែលរងរបួសចំនួន ២២នាក់ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ ដែលបង្កដោយរថយន្តដឹកថ្ម បើកជៀសរថយន្តដែលនៅខាងមុខ ក៏ជ្រុលចង្កូតទៅបុករថយន្តដឹកកម្មករពីក្រោយ បេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់សេវាព្យាបាលរហូតជាសះស្បើយ ..................................................................................១០

១០- កម្មការិនី ០៦នាក់ រងរបួសដោយរថយន្ត ១គ្រឿងម៉ាក HYUNDIA មកបុករថយន្ត ១គ្រឿងទៀតពីក្រោយពេញទំហឹងបណ្តាលឱ្យក្រឡាប់ផ្ងារជើង .............................១១

១១- បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានផ្តល់ឧបករណ៍រណប (គ្រែសម្រាប់ជនពិការសម្រាក) ដល់ជនរងគ្រោះដោយសារគ្រោះថ្នាក់ការងាររហូតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍១០០% ចំនួន ០៣នាក់ ..................................................១២

១២- កម្មករ ០៣នាក់ បានស្លាប់បាត់បង់ជីវិតភ្លាមៗនៅនឹងកន្លែង ដោយហេតុការណ៍គ្រោះថ្នាក់បាក់ផ្ទាំងថ្មភ្នំសង្កត់ នៅខេត្តបន្ទាយមានជ័យ .......................................១៣

១៣- ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ នៃបេឡាជាតិរបបសន្តិសុខសង្គម បានបំពេញភារកិច្ចរបស់ខ្លួន នៅរោងចក្រ NEW SKY PRINTION............១៤

១៤- ករណីឆ្លងចរន្តខ្សែភ្លើងនៅរោងម៉ាស៊ីនភ្លើង ក្នុងរោងចក្រ ហ៊ីវ៉ាយហ្សិនអៅឌ័របណ្តាលឱ្យកម្មករ-កម្មការិនីប្រមាណ ២១នាក់ សន្លប់ ..........................................១៥

១៥- ទស្សនគ្គពិចារណា ..................................................................................១៦

១៦- ក្រុមប្រចាំការ HOTLINE 24 ម៉ោង...........................................................១៧

១៧- អត្ថប្រយោជន៍ នៃការទទួលទាន បន្លែ និង ផ្លែឈើ .........................................១៨

១៨- សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត..........................................................១៩

១៩- បញ្ជីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបថែទាំសុខភាព ..................................................២៣

២០- បញ្ជីឈ្មោះមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ផ្នែកហានិភ័យការងារ ..................................................................................៣៤

២១- លិខិតអនុញ្ញាតបន្តអាជ្ញាប័ណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ .......................................៣៨






## រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស

លោក អ៊ុក សមវិទ្យា នាយក ប.ស.ស

ចាងហ្វាង លោក ជាវ ប៊ុនរិទ្ធ

និពន្ធនាយក លោក ឌួង ច័ន្ទតារា

និពន្ធនាយករង លោក ចាយ សំណាង

លេខានិពន្ធ លោកស្រី សុខ សុប្បស្មី

កញ្ញា យ៉េម ចន្ធូ

ផ្នែកកុំព្យូទ័រ លោក យុន វិចិត្រ

លោក ពៅ សុវណ្ណារ៉ា

លោក សុខ សុផល

# រចនាសម្ព័ន្ធគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គម



# សិក្ខាសាលាផ្សព្វផ្សាយប្រកាសអន្តរក្រសួង ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព និងកិច្ចព្រមព្រាងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាលរវាង ប.ស.ស និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព

ដើម្បីឱ្យការបម្រើសេវាសាធារណៈផ្នែកថែទាំសុខភាពមានភាពរលូន ទាន់ពេលវេលា និងមានតម្លាភាពជូនដល់សមាជិកខ្លួន ជាពិសេសកម្មករនិយោជិត បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសអន្តរក្រសួង ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព និងកិច្ចព្រមព្រាងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាលរវាង ប.ស.ស និងមូលដ្ឋានសុខាភិបាល



សិក្ខាកាមដែលជាតំណាងសហគ្រាស គ្រឹះស្ថានចូលរួមក្នុងអង្គសិក្ខាសាលា

សម្រាប់ផ្នែកថែទាំសុខភាព ដែលរៀបចំឡើងនៅសាលប្រជុំភោជនីយដ្ឋានទន្លេបាសាក់២ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **ឯកឧត្តម ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ព្រមទាំង ឯឧត្តម លោកជំទាវ អញ្ជើញមកពីក្រសួង/ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីក្រោមឱវាទជាច្រើនរូបទៀត។

ក្នុងឱកាសនោះ **លោក អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានលើកឡើងថា នៅកំឡុងពេលអនុវត្តរបបហានិភ័យការងារ ប.ស.ស បានចុះកិច្ចព្រមព្រាងជាមួយក្រសួងសុខាភិបាលបានចំនួន ៩៣ មូលដ្ឋានសុខាភិបាល ដោយមានការជ្រេជ្រាមជ្រែង និងមានការសហការល្អពីដៃគូរពាក់ព័ន្ធ ប.ស.ស បានអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ប្រកបដោយជោគជ័យទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងមានការជឿជាក់ពីកម្មករ-កម្មការិនី លើសេវាមូលដ្ឋានសុខាភិបាល។



អធិបតីចូលរួមក្នុងអង្គសិក្ខាសាលា

លោកនាយកបន្ថែមទៀតថា ប.ស.ស បច្ចុប្បន្នកំពុងបើកយុទ្ធនាការចុះបញ្ជិកាកម្មករនិយោជិត និងបន្តរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុទ្ធផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការអនុវត្តជាក់ស្តែង។ ចំពោះដំណាក់កាល និងកាលបរិច្ឆេទការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព គិតមកដល់



លោក អ៊ុក សមវិទ្យា នាយក ប.ស.ស ថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំ

បំណាច់ឆ្នាំ២០១៦នេះ ប.ស.ស អនុវត្តបាននៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ មានកម្មករនិយោជិតប្រមាណជាជាង ២០មុឺននាក់ ហើយនៅឆ្នាំបន្ទាប់សង្ឃឹមថាអាចគ្របដណ្តប់បានទូទាំងប្រទេសដូចរបបហានិភ័យការងារផងដែរ។

ទន្ទឹមនឹងការអនុវត្តន៍របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព



សម្រាប់កម្មករនិយោជិត យើងក៏មិនភ្លេចនូវភារកិច្ចថ្មីមួយទៀត ដែលប្រមុខរាជរដ្ឋាភិបាលលោកបានដាក់ជូន ដើម្បីធ្វើការសិក្សា រៀបចំ និងដាក់ឱ្យដំណើរការនូវរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការស៊ីវិល ដើម្បីឱ្យមន្ត្រីរាជការបានប្រើប្រាស់របបនេះដូចបងប្អូនកម្មករនិយោជិតផងដែរ ហើយសង្ឃឹមយ៉ាងមុខមាំថាឆ្នាំក្រោយ (ឆ្នាំ២០១៧) នេះបេឡាជាតិរបបសន្តិសុខសង្គម អាចចាប់ផ្តើមដាក់ឱ្យដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីរាជការបានដូចគ្នា។

**ឯកឧត្តមបណ្ឌិត អ៊ិតសំហេង** បានកោតសរសើរចំពោះក្រុមការងារបេឡាជោតិរបបសន្តិសុខសង្គម ប.ស.ស និងក្រុមការងារពាក់ព័ន្ធនានា ជាពិសេសក្រសួងសុខាភិបាលដែលកន្លងមកបានខិតខំប្រឹងប្រែងរួមគ្នាទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន



ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីអតិថិជន មហាជន ហើយមិនដែលគិតខ្លាចការនឿយហត់ រហូតសម្រេចបានលទ្ធផលជាច្រើនជូនក្រសួង និងកម្មករនិយោជិតនៅតាមបណ្តារោងចក្រសហគ្រាសផងដែរ។

ក្នុងឱកាសនេះដែរ **ឯកឧត្តម ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក៏បានសំដែងការកោតសរសើរ ដល់ក្រសួង



សិក្ខាកាមចូលរួមក្នុងកិច្ចប្រជុំ

ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានបេឡាជាតិរបបសន្តិសុខសង្គម ជាសេនាធិការផ្ទាល់ បានសហការគ្នាយ៉ាងស្អិតរម្មួតរួមគ្នាដោះស្រាយរាល់ចំណុចប្រឈមនានា ក្នុងការពន្លឿនសេវាសាធារណៈជូន ដល់កម្មករនិយោជិតបានតាមសំណូមពរនូវអ្វីដែលពួកគេចង់បាន៕

# ទស្សនៈកិច្ចសិក្សាផ្លូវការរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម នៅអង្គភាពសេវាកម្មសុខុមាលភាព និងជួសជុលគ្រោះថ្នាក់ការងារ នៃសាធារណៈរដ្ឋកូរ៉េ




ការថតរូបអនុស្សាវរីយ៍របស់សិក្ខាកាមចូលរួមក្នុងអង្គសិក្ខាសាលា

កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៦ ប្រធានក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម **ឯកឧត្តម សេង សក្ដា** បានដឹកនាំសមាជិកក្រុមប្រឹក្សាភិបាលចំនួន ០៥ នាក់ រួមទាំង **លោកវេជ្ជបណ្ឌិត ស៊ុំ សោភ័ណ** នាយករង នៃបេឡាជាតិរបបសន្តិសុខសង្គម អញ្ជើញទៅទស្សនៈកិច្ចសិក្សាផ្លូវការនៅអង្គភាពសេវាកម្មសុខុមាលភាព និងជួសជុលគ្រោះថ្នាក់ការងារ នៃសាធារណៈរដ្ឋកូរ៉េ។

ជាកិច្ចចាប់ផ្តើម **លោក** Lee Jae-Kap ប្រធានអង្គភាព KCOWELបានថ្លែងមតិទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូ នៃបេឡាជាតិរបបសន្តិសុខសង្គម នៃព្រះរាជាណាចក្រកម្ពុជា ដែលបានមកទស្សនៈកិច្ចនៅសាធារណៈកូរ៉េ។ លោកបានបន្តទៀតថា កិច្ចសហប្រតិបត្តិការរវាង KCOWEL និង NSSF គឺនៅតែបន្តទំនាក់ទំនងល្អជាមួយគ្នាជារៀងរហូត តាមរយៈនៃការចុះអនុស្សរណៈនៃការយោយល់គ្នាជាទ្វេភាគី (MON)។ លោកពិតជាត្រេកអរណាស់ដែលបានដឹងថា NSSF បានអនុវត្តរបបទី១ ផ្នែកធានារ៉ាប់រងហានិភ័យការងារប្រកបដោយជោគជ័យ និងបន្តដំណើរការអនុវត្តរបបទី២ ផ្នែកថែទាំសុខភាពនាឆ្នាំ២០១៦នេះ ក្នុងនោះក៏មានការចូលរួមធ្វើបទបង្ហាញដោយ **លោក** KIM IN OK ស្តីពីការចុះបញ្ជិកា និងការអេនុវត្តនៃការប្រមូលភាគទានរបស់អង្គភាពសេវាកម្មសុខុមាលភាព និងជួសជុលគ្រោះថ្នាក់ការងារ (COMWEL)។

បទបង្ហាញ ស្តីពីសេវាធានារ៉ាប់រងសំណងគ្រោះថ្នាក់ការងារផ្តោតសំខាន់លើ៖ សេវាថែទាំវេជ្ជសាស្ត្រ, តាវកាលិក, កម្មវិធីស្តារបុននីតិសម្បទា, កម្មវិធីសុខុមាលភាពការងារ, ការចុះបញ្ជិកា, និងការប្រមូលភាគទាន។

បន្ទាប់មកគណៈប្រតិភូក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម បានអញ្ជើញទៅទស្សនៈកិច្ចសិក្សានៅមន្ទីរពេទ្យស្តារបុននីតិសប្បទាដាគូ (Daegu Rehabilitation Hospital) ដោយលោកប្រធានមន្ទីរពេទ្យបានបង្ហាញ និងពន្យល់ពីសារៈសំខាន់នីមួយៗ។



ទិដ្ឋភាពនៃកិច្ចប្រជុំរួមក្នុងអង្គពិធី




ទិដ្ឋភាពការផ្តល់ជូនវត្ថុអនុស្សាវរីយ៍

# អបអរសាទរចំពោះបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលបានទទួលបណ្ណ សរសើរ ស្តីពីកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រីកសន្តិសុខសង្គមផ្នែកថែទាំសុខភាព ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA)




ការថតរូបអនុស្សាវរីយ៍

**លោក អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម បានដឹកនាំសហការី អញ្ជើញទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៣៣ នាប្រទេសហ្វីលីពីន កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ សមាគមសន្តិសុខសង្គមហ្វីលីពីន (Philippine Social Security Association, PHILSSA) ដែលមានសមាសភាពចូលរួមជាច្រើនប្រទេសដែលជាសមាជិកផងដែរ។



រូបភាពការទទួលបានបណ្ណសរសើរពីសមាគមសន្តិសុខសង្គមអាស៊ាន

គោលបំណងកិច្ចប្រជុំខាងលើនេះ ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ហើយក៏មានការចូលរួមធ្វើបទបង្ហាញស្តីអំពីសមិទ្ធិផល និងបញ្ហាប្រឈមនានាខាងផ្នែកសន្តិសុខសង្គម របស់បណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់នាពេលនោះ។

ក្នុងឱកាសនោះដែរ **លោក អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ក៏បានទទួលបណ្ណសរសើរពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ស្តីពីកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រីកសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់កម្មករ



សិក្ខាកាមជាសមាជិកអាស៊ានចូលរួមក្នុងកិច្ចប្រជុំ




និយោជិត ដែលជាមុខមាត់ថ្មីមួយបន្ថែមទៀត នៅលើឆាកអន្តរជាតិ ចំពោះការអនុវត្តរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ៕

# កិច្ចប្រជុំរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃប.ស.ស



កិច្ចប្រជុំពិភាក្សាដើម្បីពិនិត្យលើបណ្តឹងជំទាស់របស់សមាជិក ប.ស.ស

ដោយសារគណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃ ប.ស.ស ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទ ឬបណ្តឹង ដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និងបញ្ហាខាងវិស័យសន្តិសុខសង្គម រវាងសមាជិក បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) និងនិយោជក។

គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃប.ស.ស មានភារកិច្ចផ្សះផ្សាវិវាទ ដែលទាក់ទងនឹង ប.ស.ស ដូចជា៖ បណ្តឹងតវ៉ារបស់កម្មករនិយោជិត (សមាជិក ប.ស.ស) ទាក់ទងនឹងការមិនយល់ព្រម ឬភាពមិនត្រឹមត្រូវក្នុងការផ្តល់តាវកាលិក របបសន្តិសុខសង្គម, បណ្តឹងតវ៉ារបស់កម្មករនិយោជិត សមាជិក ប.ស.ស ទាក់ទងនឹងភាពមិនប្រក្រតី នៃការផ្តល់សេវារបបសន្តិសុខសង្គមជាដើម។



ដូចនេះកាលពីរសៀលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៦ បេឡាជាតិរបបសន្តិសុខសង្គមនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកិច្ចប្រជុំគណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) លើកទៅ០៩ អាណាត្តិទី០៣ ដើម្បីពិនិត្យលើបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ១១/១៦ ប.ស.ស/ជ.វ.ប ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ របស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃប.ស.ស ដែលដឹកនាំដោយ **លោក ម៉េង ហុង** នាយករង ប.ស.ស និងជាប្រធានគណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស៕



# ពិធីចែកបណ្ណបើកបរដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅសាលាស្រុកបាទី ខេត្តតាកែវ

កាលពីរសៀលថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានបើកកិច្ចប្រជុំផ្សព្វផ្សាយ និងចែកជូនបណ្ណបើកបរចំនួន ៨១បណ្ណ ដល់អ្នកបើកបរដឹកកម្មករនិយោជិត ដឹកនាំដោយ **លោក ជាវ ម៉ុនរិទ្ធ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **លោក អ៊ុក សមវិទ្យា** នាយកប.ស.ស



អធិបតីចូលរួមក្នុងកិច្ចប្រជុំ

ដែលជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត រៀបចំឡើងនៅសាលាស្រុកបាទី ខេត្តតាកែវ។

ក្នុងឱកាសនេះដែរ **លោក ជាវ ម៉ុនរិទ្ធ** ប្រធានការិយាល័យគោលនយោបាយ នៃប.ស.ស និងជាសមាជិកក្រុមការងារ បានធ្វើការណែនាំដល់អ្នកបើកបរ ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការបញ្ជាយានយន្ត ការសេពគ្រឿងស្រវឹង នឹងកត្តាផ្សេងៗទៀត ដែលនាំឱ្យបងប្អូនអ្នកបើកបរបណ្ដាលឱ្យខ្លួនមានទោសកំហុស នាំឱ្យគ្រោះថ្នាក់ ដល់អ្នករួមដំណើរជាមួយដែលនាំឱ្យខាតប្រយោជន៍ដល់ខ្លួនឯងផ្ទាល់ និងខាតប្រយោជន៍សាធារណៈផងដែរ។

លោកក៏បានលើកឡើងអំពីបទប្បញ្ញត្តិផ្សេងៗ ដែលច្បាប់ត្រូវធ្វើការពិន័យដល់អ្នកបើកបរដែលបង្កហេតុ និងមិនមានបណ្ណបើកបរស្របច្បាប់។ លោកបន្តថា ច្បាប់ចរាចរណ៍ឥឡូវនេះគឺត្រូវបានគេអនុវត្តតឹងរឹងណាស់ ដោយមិនមានការយោគយល់ចំពោះអ្នកប្រព្រឹត្តិខុសនោះឡើយ។

លោកបន្តទៀតថា បច្ចុប្បន្នក្រុមការងារ បានសហការណ៍ជាមួយក្រសួងសាធារណការណ៍ និងដឹកជញ្ជូន បានរៀបចំវគ្គបណ្ដុះបណ្ដាលច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីប្រឡងយកបណ្ណបើកបរទៅតាមប្រភេទយានយន្តឱ្យស្របតាមច្បាប់កំណត់។

ជាលទ្ធផលមានអ្នកប្រឡងជាប់ជាស្ថាពរចំនួន ១,៦០០នាក់ ក្នុងនោះប្រភេទ "ខ" ចំនួន ១,៤៦៥នាក់ ប្រភេទ "ឃ" ចំនួន ១៣៥នាក់ និងចែកបណ្ណបើកបរបានចំនួន ៩៥២បណ្ណ ក្នុងនោះនៅសាលាស្រុកបាទី ៨១បណ្ណ។ ដោយឡែកសម្រាប់គោលដៅបន្ត បេឡាជាតិរបបសន្តិសុខសង្គម និងបន្តសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូន ដើម្បីបណ្ដុះបណ្ដាលច្បាប់ ស្ដីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរដឹកកម្មករនិយោជិតជាបន្តបន្ទាប់ទៀតសម្រាប់ត្រៀមប្រឡងយកបណ្ណបើកបរ ដើម្បីឱ្យស្របតាមប្រភេទយានយន្តជាបន្តទៀត៕



សិក្ខាកាមជាតំណាងសហគ្រាសគ្រឹះស្ថានចូលរួមកិច្ចប្រជុំ



សកម្មភាពការចែកបណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត

# កិច្ចប្រជុំផ្សព្វផ្សាយអំពីការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ នៅរោងចក្រ SABRINA (CAMBODIA) GARMENT MANUFACTURING CORP

កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ, លក្ខខណ្ឌការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម, សុវត្ថិភាពចរាចរណ៍ផ្លូវគោកលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងនីតិវិធីដោះស្រាយវិវាទការងារ នៅរោងចក្រ Sabrina (Cambodia) Garment Manufacturing Corp ស្ថិតនៅឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។



សិក្ខាកាមជាកម្មករ-កម្មការិនីចូលរួមក្នុងពិធីប្រជុំ

កិច្ចប្រជុំរៀបចំឡើងក្នុងគោលបំណងចុះអប់រំ ដល់កម្មករនិយោជិតឱ្យយល់ដឹងកាន់តែច្បាស់អំពី លក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម សុវត្ថិភាពចរាចរណ៍ផ្លូវគោក លើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងនីតិវិធីដោះស្រាយវិវាទការងារ ដើម្បីឱ្យនិយោជក ក៏ដូចជាកម្មករនិយោជិតបានយល់ដឹង និងអនុវត្តឱ្យមានប្រសិទ្ធភាពនូវអ្វីដែលគណៈកម្មការ ឬក្រុមការងារបានណែនាំ ដើម្បីសុវត្ថិភាពការងារ។

ក្នុងឱកាសនេះដែរ **កញ្ញា ថុង ស្រីមុំ** តំណាងរោងចក្រ បាន



អធិបតីចូលរួមក្នុងពិធីប្រជុំ

មានមតិស្វាគមន៍ ដល់អង្គពិធីទាំងមូល ជាពិសេសបេឡាជាតិរបបសន្តិសុខសង្គម និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានចំណាយពេលវេលាដ៏មមាញឹក និងបានផ្តាំផ្ញើដល់បងប្អូនកម្មករនិយោជិតដែលបានចូលរួមនៅពេលនេះ ត្រូវយកចិត្តទុកដាក់ស្តាប់ ហើយត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនដើម្បីចូលរួមទប់ស្កាត់ករណីសន្លប់ គ្រោះថ្នាក់ចរាចរណ៍ឱ្យមានកម្រិតទាប និងបញ្ហា កុដកម្មបាតុកម្ម និងអត្ថប្រយោជន៍ផ្សេងៗពី ប.ស.ស៕



# ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត រៀបចំកិច្ចប្រជុំផ្សព្វផ្សាយ អប់រំអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់អ្នកបើកបរដឹកកម្មករនៅរោងចក្រ GHUANG LI (CAMBODIA) GARMENT Co.,ltd ខេត្តស្វាយរៀង

ដោយគ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិតពីមួយថ្ងៃទៅមួយថ្ងៃនៅតែបន្តកើតឡើងជាបន្តបន្ទាប់។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៦ កន្លងមកនេះគ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតឡើង ជាពិសេសលើមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត។

ដោយទទួលនូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តម្រូវឱ្យក្រុមការងារសុវត្ថិភាពចរាចរណ៍សម្រាប់គាំពារកម្មករនិយោជិត ត្រូវបង្កើន





និងពង្រីកការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅតាមបណ្តារោងចក្រនានា ឱ្យបានច្រើនបន្ថែមទៀត។

ដូច្នេះហើយទើបនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំអំពីច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពធ្វើដំណើររបស់កម្មករនិយោជិត ដល់អ្នកបើកបរដឹកកម្មករ ក្នុងទិសដៅចូលរួមទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត នៅរោងចក្រ GHUANG LI (CAMBODIA) GARMENT Co.,ltd ដែលមានទីតាំងស្ថិតនៅក្រុងបាវិត ខេត្តស្វាយរៀង។

កិច្ចប្រជុំធ្វើឡើងក្រោមការដឹកនាំដោយ លោកឧត្តមសេនីយ៍ត្រី លុយ ឈីន អនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត និងជាអនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ នៃអគ្គស្នងការនគរបាលជាតិ ដោយមានការចូលរួមពីអ្នកបើកបរដឹកកម្មករជាច្រើននាក់ទៀត។

ក្នុងឱកាសនេះដែរ លោកឧត្តមសេនីយ៍ត្រី លុយ ឈីន បានធ្វើបទបង្ហាញ ផ្តោតសំខាន់លើការគោរពច្បាប់ចរាចរណ៍ សុវត្ថិភាពចរាចរណ៍ផ្លូវគោក បញ្ហាបច្ចេកទេសក្នុងការត្រួតពិនិត្យ និងថែទាំយានយន្ត និងណែនាំអំពីវិជ្ជាសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ និងវិធីសាស្ត្រផ្សេងៗទៀត ដែលត្រូវយកមកអនុវត្តឱ្យបានខ្ជាប់ខ្ជួនក្នុងគោលបំណងចូលរួមទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍ឱ្យមកនូវកម្រិតមួយទាបបំផុត។



កិច្ចប្រជុំឆ្លុះបញ្ចាំងពីស្ថានភាពគ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត និងករណីដែលជាមូលហេតុបង្កឱ្យមានគ្រោះថ្នាក់នេះ ដើម្បីចូលរួមចំណែកទប់ស្កាត់ បង្ការ និងអនុវត្តទៅតាមច្បាប់ជាធរមាន។

បន្ថែមពីនេះលោកឧត្តមសេនីយ៍ត្រី បានផ្តាំផ្ញើដល់អ្នកបើកបរដឹកកម្មករទាំងអស់ត្រូវបើកបរឱ្យបានត្រឹមត្រូវតាមច្បាប់ និងបើកបរដោយមានទំនួលខុសត្រូវខ្ពស់ ពីព្រោះជីវិតរាប់សិបនាក់របស់បងប្អូនកម្មករនិយោជិតបានផ្ញើវាសនាលើអ្នកបើកបរតែម្នាក់ប៉ុណ្ណោះ។ លោកបានបន្ថែមទៀតថាអ្នកបើកបរត្រូវប្រកាន់នូវពាក់ស្លោកដែលមានខ្លឹមសារថា "ថ្ងៃនេះថ្ងៃស្អែកកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍"។

# កម្មករ-កម្មការិនី ដែលរងរបួសចំនួន ២២ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ដែលបង្កដោយរថយន្តដឹកថ្ម បើកជៀសរថយន្តដែលនៅខាងមុខ ក៏ជ្រុលចង្កូតទៅបុករថយន្តដឹកកម្មករពីក្រោយ បេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់សេវាព្យាបាលរហូតជាសះស្បើយ

បច្ចុប្បន្ននេះបញ្ហាគ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតឡើងជារៀងរាល់ថ្ងៃ បានបណ្តាលឲ្យមានអ្នកស្លាប់ របួសដែលបានបន្សល់ទុកនូវសោធនាដកម្មដ៏រន្ធត់បំផុតចំពោះឧបទ្ទវហេតុដែលកើតឡើងនេះ។ ព្រមទាំងបាត់បង់ធនធានមនុស្សសម្រាប់អភិវឌ្ឍន៍ជាតិ ខាតបង់ថវិការរដ្ឋ ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ និងបានបន្សល់ទុកនូវកុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ និងទុរគត់ជនជាច្រើននាក់។






ការចុះពិនិត្យ និងជួយសម្របសម្រួលរបស់មន្ត្រី ប.ស.ស នៅកន្លែងកើតហេតុ និងនៅមន្ទីរពេទ្យ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាបេឡាជាតិរបបសន្តិសុខសង្គម និងក្រសួងដែលពាក់ព័ន្ធ បានអំពាវនាវដល់បងប្អូនដឹកកម្មករ-កម្មការិនី និងប្រជាពលរដ្ឋទាំងអស់ឲ្យធ្វើដំណើរដោយគោរពច្បាប់ចរាចរណ៍ ធ្វើដំណើរត្រូវមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការបើកបរ ដើម្បីកុំអោយមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ស្របទៅនឹងសម្តេចតេជោហ៊ុនសែនបានមានប្រសាសថា "ថ្ងៃនេះ ថ្ងៃស្អែកសូមកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍" កើតឡើង។

មុនពេលកើតហេតុគេឃើញរថយន្តទាំង២គ្រឿង បើកស្របទិសគ្នា លុះមកដល់ចំណុចកើតហេតុស្រាប់តែរថយន្តដឹកថ្មបានបើកជៀសរថយន្តមួយគ្រឿងទៀតដែលនៅខាងមុខ ក៏បានជ្រុលចង្កូតទៅបុកចំពីក្រោយរថយន្តដឹកកម្មករយ៉ាងពេញទំហឹងតែម្តង។

ហេតុការណ៍គ្រោះថ្នាក់ខាងលើនេះ មន្ត្រីសាខា ប.ស.ស ខេត្តបានចុះជួយសម្របសម្រួល និងបញ្ជូនជនរងគ្រោះទៅសម្រាកព្យាបាលនៅមន្ទីរពិនិត្យព្យាបាល ជា សុខលឹម ចំនួន២១នាក់ និង ០១នាក់ ទៀតសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តតាកែវ។



រូបភាពជនរងគ្រោះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ

ចំពោះជនរងគ្រោះទាំង ២២នាក់ ត្រូវទទួលបានអត្ថប្រយោជន៍ពីបេឡាជាតិរបបសន្តិសុខសង្គម លើការចំណាយលើមធ្យោបាយដឹកជញ្ជូន និងសេវាព្យាបាលរហូតជាសះស្បើយ និងអត្ថប្រយោជន៍ផ្សេងៗទៀតរួមមាន៖ ការសង្គ្រោះបន្ទាន់ ការព្យាបាលរហូតជាសះស្បើយទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ (គិតចាប់ពីថ្ងៃទី០២ បន្ទាប់ពីថ្ងៃគ្រោះថ្នាក់)៕

# កម្មការិនី ០៦នាក់ រងរបួសដោយរថយន្ត ១គ្រឿងម៉ាក HYUNDAI មកបុករថយន្ត ១គ្រឿងទៀតពីក្រោយពេញទំហឹងបណ្ដាលឱ្យក្រឡាប់ផ្ងារជើង

ករណីគ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតឡើងជារៀងរាល់ថ្ងៃ បណ្ដាលឲ្យមានអ្នកស្លាប់ របួស និងពិការបានបន្សល់ទុក្ខនូវសោធនាដកម្មដ៏រន្ធត់បំផុតចំពោះឧបទ្ទវហេតុដែលកើតឡើងនេះ ព្រមទាំងបាត់បង់ធនធានមនុស្សសម្រាប់អភិវឌ្ឍន៍ជាតិ ខាតបង់ថវិការដ្ឋ ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ និងបានបន្សល់ទុក្ខនូវកុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ និងទុរគត់ជនជាច្រើននាក់។







រូបភាពជនរងគ្រោះសម្រាក់ព្យាបាលនៅមន្ទីរពេទ្យ

កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ មានករណីគ្រោះថ្នាក់ចរាចរណ៍ បានកើតឡើងនៅតាមបណ្ដោយផ្លូវជាតិលេខ៥ ត្រង់ចន្លោះគីឡូម៉ែត្រលេខ ១៥៨-១៥៩ ស្ថិតក្នុង ភូមិសារវ័ន្ត ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិសាត់។ ករណីគ្រោះថ្នាក់ខាងលើបង្កឱ្យកម្មការិនីចំនួន ០៦នាក់ រងរបួសស្រាលក្នុងចំណោមកម្មករ ៤៥នាក់។

មុនពេលកើតហេតុគេឃើញរថយន្ត៣គ្រឿង បើកស្របទិសគ្នាពីលិចទៅកើត លុះមកដល់ចំណុចកើតហេតុមានរថយន្ត ០១ គ្រឿងម៉ាក HYUNDAI ពាក់ស្លាកលេខភ្នំពេញ 3B-3951 ជ្រុលទៅបុកចំពីក្រោយយ៉ាងពេញទំហឹងនឹងរថយន្តម៉ាក HYUNDAI ប្រភេទ ៥តោន ក្រឡាប់ផ្ងារជើងហើយរថយន្តបង្កបានជ្រុលចង្កូតទៅបុករថយន្តមួយគ្រឿងទៀតម៉ាក HYUNDAI ដូចគ្នាចំពីមុខតែម្ដង។

ហេតុការណ៍គ្រោះថ្នាក់នេះដែរ មន្ត្រីសាខា ប.ស.ស ខេត្តបានចុះជួយសម្របសម្រួលបញ្ជូនជនរងគ្រោះទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកស្រុកក្រគរ ខេត្តពោធិ៍សាត់។ ចំពោះការចំណាយលើមធ្យោបាយដឹកជញ្ជូន និងសេវាព្យាបាល ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

រាជរដ្ឋាភិបាល ក៏ដូចជាបេឡាជាតិរបបសន្តិសុខសង្គម និងក្រសួងពាក់ព័ន្ធបានអំពាវនាវ ដល់បងប្អូនដឹកកម្មករ-កម្មការិនី និងប្រជាពលរដ្ឋទាំងអស់ឲ្យធ្វើដំណើរដោយមានការប្រុងប្រយ័ត្នទ្វេរដងក្នុងការបើកបរ ដើម្បីកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ស្របទៅនឹងសម្ដេចតេជោហ៊ុនសែនបានមានប្រសាសន៍ថា “ថ្ងៃនេះថ្ងៃស្អែកសូមកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍” កើតឡើង។

# បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានផ្តល់ឧបករណ៍រណប (គ្រែសម្រាប់ជនពិការសម្រាក) ដល់ជនរងគ្រោះដោយសារគ្រោះថ្នាក់ការងារបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍១០០% ចំនួន០៣នាក់

បេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់ឧបករណ៍រណប (គ្រែសម្រាប់ជនពិការសម្រាក)ដល់ជនរងគ្រោះដោយសារគ្រោះថ្នាក់ការងារចំនួន ០៣នាក់, និងត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដល់អ្នកថែទាំ, ប្រាក់បំណាច់ប្រចាំខែ (បើកផ្តល់ប្រាក់ឧបត្ថម្ភឱ្យមួយជីវិត) និងអត្ថប្រយោជន៍ដទៃទៀត...។

កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ក្រុមការងាររៀបចំយន្តការផ្តល់សេវាបុននីតិសម្បទា និងការិយាល័យតាវកាលិក នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបន្ទាយព្រាប ដែលដឹកនាំដោយ **លោក កែវ ម៉ុនណា** ប្រធានការិយាល័យតាវកាលិក បានចុះប្រគល់គ្រែសម្រាប់ជនពិការរបួសខ្សួរឆ្អឹងខ្នង ដែលជាសមាជិក ប.ស.ស ចំនួន ០៣នាក់ រួមមាន៖

- ជនរងគ្រោះឈ្មោះ **ឆេង ចន្ថា** ភេទស្រី អាយុ ៣៧ឆ្នាំ មានទីលំនៅភូមិរំលោះ សង្កាត់រំលោះ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ



ធ្លាប់ធ្វើការនៅសហគ្រាស ហ្វរើសអិនដាស់ស្ទ្រីលខប ផ្នែកវេចខ្ចប់ រងគ្រោះដោយសារគ្រោះថ្នាក់ចរាចរណ៍ បណ្តាលឱ្យបាក់ឆ្អឹងកងក និងរបួសផ្នែកក្បាល (ពិការពីកចុះក្រោម)។

- ជនរងគ្រោះឈ្មោះ **ខៃ ខឿម** ភេទប្រុស អាយុ ២៧ឆ្នាំ នៅលីវ មានទីលំនៅភូមិទ័ពបោះ សង្កាត់ព្រៃវែង ខ័ណ្ឌដង្កោ រាជធានី



មន្ទីរ ប.ស.ស បានចុះផ្តល់ឧបករណ៍រណប ដល់ជនរងគ្រោះ

ភ្នំពេញ ធ្លាប់ធ្វើការនៅសហគ្រាស ថាណាវលេឌើរហ្គូដស៍មេន្ទហ្វេកធឺរី ផ្នែកជាងផ្សា រងគ្រោះដោយសារកាំជណ្តើរធ្លាក់លើពេលកំពុងធ្វើការ បណ្តាលឱ្យបាក់ឆ្អឹងខ្នង និងត្រូវក្បាល (ពិការត្រឹមចង្កេះចុះក្រោម)។



- ជនរងគ្រោះឈ្មោះ **តែ សំអុល** ភេទស្រី អាយុ ៣៦ឆ្នាំ នៅលីវ មានទីលំនៅភូមិស្រែរាំង ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ធ្លាប់ជាបុគ្គលិកសហគ្រាស ថៃយ៉ាហ្គាមេនអ៊ិនដាសស្ទ្រីល ទទួលរងគ្រោះថ្នាក់ ដោយសាររថយន្តកៀររ៉ឺម៉ក បណ្តាលឱ្យរងរបួសផ្លោកនោម និងបាក់ឆ្អឹងចង្កេះ៕

# កម្មករ ០៣នាក់បានស្លាប់បាត់បង់ជីវិតភ្លាមៗនៅនឹងកន្លែង ដោយហេតុការណ៍គ្រោះថ្នាក់ បាក់ផ្ទាំងថ្មភ្នំសង្កត់ នៅខេត្តបន្ទាយមានជ័យ

ហេតុការណ៍គ្រោះថ្នាក់ដ៏រន្ធត់មួយបានកើតឡើងកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ នៅវេលាម៉ោង ១២ និង៥០នាទីថ្ងៃត្រង់ បណ្តាលមកពីផ្ទាំងថ្មបាក់សង្កត់អ្នកបើកគ្រឿងចក្រអេស្កាកាយថ្ម ស្លាប់ចំនួន ៣នាក់នៅការដ្ឋានវាយថ្មសហគ្រាសភ្នំធំ៣លឹមហេង មានទីតាំងស្ថិតនៅភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

ជនរងគ្រោះខាងលើមាន៖ ឈ្មោះ លឹម គឹមឡេង អយុ ៥២ឆ្នាំ, ឈ្មោះ លឹម គឹមឡុង អាយុ ២៦ឆ្នាំ, និងឈ្មោះ ថន ស៊ីថា អាយុ ៣៧ឆ្នាំ។ ជនរងគ្រោះទាំង ០៣នាក់ខាងលើ រស់នៅភូមិភ្នំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គល់បូរី ខេត្តបន្ទាយមានជ័យ។

ហេតុការណ៍គ្រោះថ្នាក់នេះ កើតឡើងខណៈពេលដែលជនរងគ្រោះ ឈ្មោះ ហែម គឹមលេង បានបើកអេស្កាកាយថ្មភ្នំ នៅខាងលើកំពូលភ្នំធំ ដែលមានកម្ពស់ប្រមាណជាង ២០០ម៉ែត្រ នៅពេលកំពុងកាយថ្ម ស្រាប់តែកំពូលភ្នំបានបាក់ធ្លាក់មកក្រោមបានសង្កត់អេស្កាវ៉ាទ័រ ចំនួន ២គ្រឿង និងម៉ាស៊ីនឃ្លូង១គ្រឿង បណ្តាលឱ្យស្លាប់ភ្លាមៗនៅកន្លែងកើតហេតុទាំង ០៣នាក់ ដោយសាកសពរបស់ជនរងគ្រោះ ២នាក់ មានសភាពបែកជាបំណែកខ្ទេចខ្ទីមើលមិនស្គាល់។

ក្រោយពីទទួលព័ត៌មានភ្លាមមន្ត្រី ប.ស.ស ខេត្តបានសហការជាមួយរដ្ឋបាលសហគ្រាស ដើម្បីបញ្ជូនសពជនរងគ្រោះទៅលំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី។ ចំពោះជនរងគ្រោះដែលបានស្លាប់ទាំង ០៣នាក់ ត្រូវទទួលបានអត្ថប្រយោជន៍ពី ប.ស.ស ក្នុងការចាត់ចែងបូជាសពចំនួន ៤.០០០.០០០ រៀលផ្តល់ជូនដល់អ្នកនៅក្នុងបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ និងសិទ្ធិវន្ត ជាប្រពន្ធ ឬប្តីនៃជនរងគ្រោះ ត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ សិទ្ធិទទួលធនលាភចំពោះសិទ្ធវន្ត ជាប្រពន្ធ ឬប្តីត្រូវបានរំលាយនៅពេលដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី ចំពោះសិទ្ធិវន្តជា កូនត្រូវមានស្ថានភាពស្របតាមលក្ខខណ្ឌនៃសហព័ន្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជី អត្រានុកូលដ្ឋានត្រឹមត្រូវ។ ចំណែកសិទ្ធិទទួលធនលាភចំពោះជនចាស់ជរា នៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីទទួលមរណភាព៕







# ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ នៃបេឡាជាតិ របបសន្តិសុខសង្គម បានបំពេញភារកិច្ចរបស់ខ្លួន នៅរោងចក្រ New Sky Printion

ទោះបីជាមានការផ្សព្វផ្សាយ និងណែនាំបានទូលំទូលាយយ៉ាងណាក៏ដោយ ក៏នៅតែកើតមានករណីសន្លប់នេះកើតឡើងច្រើនទៀត។ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោងប្រមាណ ០៩ និង១០ នាទីព្រឹក មានករណីកម្មករសន្លប់នៅរោងចក្រ New Sky Printion ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ២១៧ ភូមិបាគូ ស្រុកជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ មានកម្មករសន្លប់ប្រមាណ ១៧នាក់។



កិច្ចប្រជុំពិភាក្សារកមូលហេតុដែលបណ្តាលឱ្យកម្មករសន្លប់

ករណីនេះផ្តើមចេញពីកម្មការនីម្នាក់មានអាការៈមិនស្រួលខ្លួនងងឹតមុខដួលតែម្តង ដោយឃើញសភាពបែបនេះ ក៏បណ្តាលឲ្យមានការដួលសន្លប់តៗគ្នារហូតដល់ច្រើននាក់ថែមទៀត។ បែបនេះហើយ អ្នកបច្ចេកទេសបានឲ្យឈ្មោះថាជា "ជម្ងឺស្នេហ៍ហ្វូង"។

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម បានចុះអង្កេតសិក្សាស្រាវជ្រាវរកមូលហេតុ និងណែនាំ ហើយបានកំណត់ថាៈ មូលហេតុដែលកើតឡើងគឺៈទី១ របបចំណីអាហារ ទី២អារម្មណ៍ផ្លូវចិត្ត ទី៣ ជម្ងឺប្រចាំកាយ ទី៤លក្ខខណ្ឌការងារ(ការបំពាក់គ្រឿងលំហូរចេញ-ចូលខ្យល់មិនបានគ្រប់គ្រាន់ក្នុងរោងចក្រ)។

ការសម្របសម្រួលនៅមន្ទីរពេទ្យ (ថ្លៃដឹកជញ្ជូនជនរងគ្រោះ និងថ្លៃព្យាបាល ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ទាំងស្រុង ។



ការវាស់ស្ទង់ពីសីតុណ្ហភាពនៅកន្លែងកើតហេតុ



រូបភាពការសម្រាកព្យាបាលរបស់បងប្អូនកម្មករ-កម្មការិនីនៅក្នុងមន្ទីរពេទ្យ

# ករណីឆ្លងចរន្តខ្សែភ្លើងនៅរោងម៉ាស៊ីនភ្លើង ក្នុងរោងចក្រ ហឺវ៉ាយហ្សិនអៅឌ័រ បណ្តាលឱ្យកម្មករ-កម្មការិនីប្រមាណ ២១នាក់ សន្លប់

កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោងប្រមាណ ១២ និង១៥នាទីថ្ងៃត្រង់ មានករណីឆ្លងចរន្តភ្លើងនៅរោងម៉ាស៊ីនភ្លើង ក្នុងរោងចក្រ ហឺវ៉ាយហ្សិន អៅឌ័រ បណ្តាលឱ្យកម្មករភ័យតក់ស្លុត សន្លប់តៗគ្នាប្រមាណ ២១នាក់។

ករណីនេះមន្ត្រីសាខា ប.ស.ស ខេត្តបានចុះទៅជួយសម្របសម្រួលជាមួយរដ្ឋបាលរោងចក្រ និងបញ្ជូនជនរងគ្រោះទៅព្យាបាលនៅគ្លីនិច តែ វណ្ណា។ រាល់ការចំណាយលើសេវាព្យាបាលរហូតជាសះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។



ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម បានចុះអង្កេតសិក្សាស្រាវជ្រាវរកមូលហេតុ និងណែនាំ ហើយបានកំណត់ថា: មូលហេតុដែលកើតឡើងគឺ: ផ្តើមចេញពីអារម្មណ៍ភ័យខ្លាចតក់ស្លុត ទន់ដៃ ទន់ជើង បណ្តាលឱ្យសន្លប់៕



ការសម្របសម្រួលនៅមន្ទីរពេទ្យ (ថ្លៃដឹកជញ្ជូនជនរងគ្រោះ និងថ្លៃព្យាបាល) ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ទាំងស្រុង ។



ការសម្រាក់ព្យាបាលរបស់បងប្អូនកម្មករ-កម្មការិនីនៅក្នុងមន្ទីរពេទ្យ

# ទស្សនគ្គរពិចារណា














# ទូរស័ព្ទៈ ១២៨៦

# ក្រុមប្រចាំការ Hotline 24 ម៉ោង

ដើម្បីធ្វើឱ្យការងារទទួលព័ត៌មានពីជនរងគ្រោះដែលជាកម្មករនិយោជិតបម្រើការងារ នៅតាមបណ្ដាសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គមឱ្យ កាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលាជាងមុន បេឡាជាតិរបបសន្តិសុខសង្គម បានបង្កើតឱ្យមានក្រុមការងារប្រចាំការមួយឡើង មានភារកិច្ចរង់ចាំទទួលព័ត៌មានពីករណីដែលមានគ្រោះថ្នាក់ការងារកើតឡើង ហើយតម្រូវឱ្យមានការសង្គ្រោះបន្ទាន់។

ក្នុងករណីនេះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ឬកម្មករនិយោជិត ត្រូវជូនដំណឹងមកកាន់បេឡាជាតិរបបសន្តិសង្គម ជាបន្ទាន់តាមរយៈក្រុមការងារប្រចាំការដែលមានលេខទូរស័ព្ទទំនាក់ទំនងសំរាប់សេវាសង្គ្រោះបន្ទាន់ ( Hotline ) **១២៨៦**។



លេខទូរស័ព្ទនេះអាចធ្វើការហៅចូលបានគ្រប់ប្រព័ន្ធដោយឥតគិតថ្លៃ និងមានបុគ្គលិកប្រចាំការរង់ចាំទទួលព័ត៌មាន ២៤ម៉ោងលើ២៤ម៉ោង។ ដោយឡែកចំពោះការសាកសួរព័ត៌មានផ្សេងទៀតក្រៅពីសេវាសង្គ្រោះបន្ទាន់ សូមទាក់ទងតាមប្រព័ន្ធទូរស័ព្ទ ០២៣ ៨៨២ ៦២៣ និង ០២៣ ៨៨២ ៨៣៤ វិញ។

តាមរយៈការដាក់ឱ្យដំណើរការប្រព័ន្ធទូរស័ព្ទទំនាក់ទំនងបន្ទាន់នេះ បេឡាជាតិរបបសន្តិសុខសង្គម បានទទួលនូវព័ត៌មានពីសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតពីករណីគ្រោះថ្នាក់ ការងារបានមួយចំនួន បានជួយសម្របសម្រួលចំពោះសេវាសង្គ្រោះបន្ទាន់បានជាច្រើនករណី និង ទាន់ពេលវេលា។ ក្រៅពីនោះក្រុមការងារបានសម្របសម្រួលសេវាទំនាក់ទំនងផ្ទាល់មាត់ មាន ភាពសកម្ម ដោយមានការពេញចិត្តពីសមាជិក ប.ស.ស ផងដែរ។

ទន្ទឹមនឹងការអនុវត្តការងារបានល្អ ក្រុមការងារក៏នៅជួបបញ្ហាប្រឈមមួយចំនួន ដែលតម្រូវឱ្យក្រុមការងាររិះរកគ្រប់នីតិវិធី ដើម្បីឱ្យការផ្ដល់ និងការបម្រើសេវាជូនដល់សមាជិករបស់ខ្លួន ឱ្យមានភាពរលូន ទាន់ពេលវេលា និងមានភាពឆាប់រហ័សជាងមុនបន្ថែមទៀត។

# អត្ថប្រយោជន៍ នៃការទទួលទាន បន្លែ និង ផ្លែឈើ

### សារៈប្រយោជន៍ នៃការទទួលទាន "ទំពាំងបាយជូរ"

- កាត់បន្ថយជំងឺបេះដូង និងសរសៃឈាម
- ប្រឆាំងការរលាក និងមេរោគ
- ជួយឲ្យក្មេងជាងវ័យ
- ការពារតម្រងនោម
- ការពារជំងឺតម្រងនោម និងប្រព័ន្ធទឹកនោម
- ប្រឆាំងជំងឺមហារីក
- សំបូរវីតាមីន និងសារជាតុរ៉ែ




### សារៈប្រយោជន៍ នៃការទទួលទាន "ផ្លែម្នាស់"

- ទប់ស្កាត់មេរោគ
- ស្បែកស្រស់ថ្លា
- សម្អាតម្រងនោម
- ភ្នែកភ្លឺច្បាស់



- ជំនួយឆ្អឹង
- គ្រប់គ្រងជំងឺសន្លាក់

### សារៈប្រយោជន៍ នៃការទទួលទាន "ប៉េងប៉ោះ"

- ពង្រឹងដល់សុខភាពភ្នែក និងពោះវៀន
- ប្រឆាំងជំងឺមហារីក
- ជួយឲ្យប្រព័ន្ធការពាររាងកាយរឹងមាំ
- ការពារស្បែក
- ទប់ស្កាត់ជំងឺបេះដូង
- សំបូរវីតាមីន និងជាតិរ៉ែ
- កាឡូរីទាប (មិនងាយធាត់)



### សារៈប្រយោជន៍ នៃការទទួលទាន "ផ្លែប័រ"

- សម្រាប់ស្ត្រីមានផ្ទៃពោះ និងបង្ការជំងឺទារកពីកំណើត
- ជំនួយភ្នែក
- សម្រួលការរំលាយអាហារ
- ពង្រឹងប្រព័ន្ធភាពស៊ាំ



- ជួយបញ្ចុះកូឡេស្តេរ៉ុល
- ជំនួយស្បែក
- គ្រប់គ្រងសម្ពាធឈាម
- ជំនួយបេះដូង

### សារៈប្រយោជន៍ នៃការទទួលទាន "ការ៉ុត"

- មិនងាយទទួលជំងឺ
- ជួយឲ្យឆាប់រំលាយអាហារ
- ប្រឆាំងមេរោគ និងបាក់តេរី
- ជំនួយស្បែក និងភ្នែក



- កាត់បន្ថយជំងឺបេះដូង និងមហារីក
- ជួយឲ្យធ្មេញ និងអញ្ចាញមានសុខភាពល្អ
- ពង្រឹងសុខភាពថ្លើម និងតម្រងនោម

### សារៈប្រយោជន៍ នៃការទទួលទាន "ផ្លែខ្វិត"

- ជួយរំលាយអាហារ
- បង្កើនថាមពល
- បង្ការបញ្ហាខ្វះវីតាមីន C
- ជំនួយសុខភាពថ្លើម
- ការពារជំងឺគ្រុនចាញ់



- ជួយលាងឈាម
- ជំនួយតម្រងនោម
- សម្រួលបញ្ហាផ្លូវដកដង្ហើម

# សាខា ប.ស.ស តាមបណ្តារាជធានី / ខេត្ត

| ខេត្តកណ្តាល | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ផ្ទះលេខ០១ ផ្លូវលេខ២០២, ភូមិដើមមៀន, សង្កាត់ដើមមៀន, ក្រុងតាខ្មៅ, ខេត្តកណ្តាល | ០៨៥ ៥៦៧ ៧៦៦<br>០៧៧ ៩៦៣ ០៧៨ | ០២៤ ៦៤០ ១៦៧៦ | samphearak@nssf.gov.kh |
| **ខេត្តកណ្តាល** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ភូមិក្នុង, ឃុំព្រែកតាមាក់, ស្រុកខ្សាច់កណ្តាល, ខេត្តកណ្តាល | ០៩៦ ៦១៥ ៦១៦៨<br>០១២ ៥៤៨ ៨០៥<br>០៩៨ ៥៤៨ ៨០៥ | ០២៣ ៥១៩ ៨៩៩៩ | nssf_reythearith@nssf.gov.kh |
| **ខេត្តកំពង់ស្ពឺ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខ៣៦A ភូមិស្វាយជ្រុំ, ឃុំបែកចាន, ស្រុកអង្គស្នួល, ខេត្តកណ្តាល | ០១២ ២៨៦ ៨៧៩<br>០១៥ ២១០ ២១០<br>០៦០ ២១២ ២១២ | ០២៤ ៥០៨ ០៧៧៧ | movratha@yahoo.com |
| **ខេត្តព្រះសីហនុ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ សង្កាត់លេខ០៤, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ | ០១៧ ៩៣៣ ៣៩៦<br>០៧៧ ៦៦៣ ២១៥ | ០៣៤ ៩៣៤ ៦០៦ | tong_samnieng@nssf.gov.kh |
| **ខេត្តស្វាយរៀង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្លូវជាតិលេខ០១, ភូមិបាវិតលើ, សង្កាត់បាវិត, ក្រុងបាវិត, ខេត្តស្វាយរៀង | ០៧៧ ៦៦៣ ២១៤ | ០៤៤ ៧១៥ ៨៣១ | pek.samol@nssf.gov.kh |
| **ខេត្តកំពង់ឆ្នាំង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខC៤៩៥, ក្រុមទី១៨, ភូមិម៉ុងបារាំង, សង្កាត់ប្អេរ, ក្រុងកំពង់ឆ្នាំង, ខេត្តកំពង់ឆ្នាំង | ០៧៧ ៦៦៣ ២១៦<br>០១៦ ៨៨៤ ៣៤៨ | ០២៦ ៩៨៨ ៨៩១<br>០២៦ ៧៧៥ ៥៦៦ | nssf_kcn@nssf.gov.kh |
| **ខេត្តសៀមរាប** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខP១០, ភូមិត្រពាំងសេះ, ឃុំគោកចក, ក្រុងសៀមរាប, ខេត្តសៀមរាប | ០១២ ៥៣៤ ៣៤៥<br>០៧៧ ៦៦៣ ២១៧ | ០៦៣ ៩៦៥ ៩៣៤ | pang_sokchea@yahoo.com<br>sokchea@nssf.gov.kh |

| ខេត្តបន្ទាយមានជ័យ | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ភូមិគីឡូម៉ែត លេខ០៤, សង្កាត់ផ្សារកណ្ដាល, ក្រុងប៉ោយប៉ែត, ខេត្តបន្ទាយមានជ័យ | ០៧៧ ៦៦៣ ២១៨<br>០៨៩ ៩៨៧ ៨៨៧ | ០៥៤ ៧១១ ៩៤១ | nssf_bmc@nssf.gov.kh |
| **ខេត្តកំពង់ចាម** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ភូមិទី១៤, សង្កាត់វាលវង់, ក្រុងកំពង់ចាម, ខេត្តកំពង់ចាម | ០១២ ៥២០ ៧៦៧<br>០៧៧ ៩៩០ ០៤៨ | ០៤២ ៦៥២ ១៩៩៩<br>០៤២ ៩៤៣ ៣៨៨ | say.sothon@nssf.gov.kh |
| **ខេត្តព្រៃវែង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខ១០៧, ភូមិលេខ៣, សង្កាត់កំពង់លាវ, ក្រុងព្រៃវែង, ខេត្តព្រៃវែង | ០១២ ៥៤៨ ៨០៥<br>០៩២ ៧០៨ ៨០៣ | | reythearith@yahoo.com<br>rey.thearith@nssf.gov.kh |
| **ខេត្តតាកែវ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្លូវលេខ១០, ភូមិ០២, សង្កាត់រកាក្នុង, ក្រុងដូនកែវ, ខេត្តតាកែវ | ០១២ ៦៣៦ ៤៣៩ | ០៣២ ២១០ ៦៦៦ | vannak-rk@nssf.gov.kh<br>vannaknssf@gmail.com |
| **ខេត្តស្ទឹងត្រែង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ភូមិថ្មលាត, សង្កាត់ស្រះឫស្សី, ក្រុងស្ទឹងត្រែង, ខេត្តស្ទឹងត្រែង | ០១២ ៤០៥ ៤៥១ | | nganrachana@gmail.com |
| **ខេត្តក្រចេះ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្លូវជាតិលេខ៧៣, ភូមិរកាកណ្ដាលទី០១, សង្កាត់រកាកណ្ដាល, ក្រុងក្រចេះ, ខេត្តក្រចេះ | ០៩២ ៨៧៣ ០៥១<br>០៩៧ ២៦២ ៧៥៤៧ | ០៧២ ២១០ ៤២៣ | kratie@nssf.gov.kh<br>soksay.he@nssf.gov.kh |

| ខេត្តកំពត | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋាន: ភូមិ០១ឧសភា, ឃុំកំពង់កណ្ដាល, ស្រុកកំពង់បាយ, ក្រុងកំពត, ខេត្តកំពត | ០១២ ៦២៣ ៣៣២<br>០៧២ ៦៨៨ ៨៨៦ | ០៣៣ ៩៣២ ១៣៣ | phokchetra@gmail.com sin.kosal@nssf.gov.kh |
| **ខេត្តពោធិ៍សាត់** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ផ្ទះលេខ០០៧, ភូមិរ៉ា, សង្កាត់ផ្ទះព្រៃ, ក្រុងពោធិ៍សាត់, ខេត្តពោធិ៍សាត់ | ០៩២ ៧០៧ ៣៨៥ | ០៥២ ៩៥១ ១២៣ | nssf_ps@nssf.gov.kh |
| **ខេត្តបាត់ដំបង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ផ្ទះលេខB០៩, បូរីពាណិជ្ជកម្មបាត់ដំបង, សង្កាត់ស្វាយប៉ោ, ក្រុងបាត់ដំបង, ខេត្តបាត់ដំបង | ០៩៧ ៩៩៧ ២៨២៩ | ០៥៣ ៩៥៣ ៣៣៦ | battambang@nssf.gov.kh |
| **ខេត្តកោះកុង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ផ្ទះលេខ២៦, ក្រុម២, ភូមិ៣, សង្កាត់ដងទង់, ក្រុងខេមរភូមិន្ទ, ខេត្តកោះកុង | ០៩៧ ៩៧៣ ៩០០៦<br>០១២ ៦២៥ ៨៥៥ | ០៣៥ ៩៣៦ ៤៣៦ | kongkea.nssf.kk@gmail.com |
| **ខេត្តប៉ៃលិន** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ភូមិវត្ត, សង្កាត់ប៉ៃលិន, ក្រុងប៉ៃលិន, ខេត្តប៉ៃលិន | ០៨៦ ៨៩៣ ៧៧៧ | ០៥៥ ៩៥៦ ៦៦៧ | somit.ream@nssf.gov.kh |
| **ខេត្តកំពង់ធំ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ភូមិទី០៧, សង្កាត់កំពង់ធំ, ក្រុងស្ទឹងសែន, ខេត្តកំពង់ធំ | ០៩២ ៧៤៧ ០៩៩ | ០៦២ ២១០ ៤៦៣ | ly_sokha2007@yahoo.com |

| ខេត្តរតនគិរី | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ភូមិទេសអន្លង់, សង្កាត់បឹងកន្សែង, ក្រុងបាលុង, ខេត្តរតនគិរី | ០១១ ៩៥១ ៧៧៧<br>០៩៧ ៩៦៦ ៧៦៦៦ | ០៧៥ ៩៧៤ ១៨៤ | sam_ath@nssf.gov.kh |

| ខេត្តមណ្ឌលគិរី | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ភូមិចំបក់, សង្កាត់ស្ពានមានជ័យ, ក្រុងសែនមនោរម្យ, ខេត្តមណ្ឌលគិរី | ០១២ ២០៥ ៧៥៦<br>០៨៨ ៨២០ ៥៧៥៦ | | kosol_vicheth@yahoo.com |

| ខេត្តឧត្តរមានជ័យ | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ភូមិឈ្សូក, សង្កាត់សំរោង, ក្រុងសំរោង, ខេត្តឧត្តរមានជ័យ | ០៩៧ ៥២៣ ៨៦៦៦<br>០៨៥ ៣១១ ៣០០ | | simmao2013@gmail.com |

| ខេត្តព្រះវិហារ | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ភូមិកណ្តាល, សង្កាត់កំពង់ប្រណាក, ក្រុងព្រះវិហារ, ខេត្តព្រះវិហារ | ០៩៧ ៣៦៦ ៦០៦ ០<br>០១២ ២៥៩ ២៥៨ | | nssf_pvh@nssf.gov.kh<br>savuthnou22@gmail.com |

| សាខា ប.ស.ស ខណ្ឌដង្កោ | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ផ្ទះលេខ១២A, ផ្លូវវេងស្រេង, សង្កាត់ចោមចៅ, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ, (ទល់មុខផែរស្វែតស្វរង្វេន) | ០១២ ៦៩៥ ៥៥០<br>០៨៦ ២៧១ ៣៧១ | ០២៣ ៩៩៥ ៨៨៤ | lpl@nssf.gov.kh |

| សាខា ប.ស.ស ខណ្ឌឬស្សីកែវ | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ផ្ទះលេខ៥០EoE1, ផ្លូវលេខ០៣, ភូមិបឹងឈ្សូក, សង្កាត់គីឡូម៉ែត្រ០៦, ខណ្ឌឬស្សីកែវ, រាជធានីភ្នំពេញ | ០៩២ ៨៨៦ ២៥៦<br>០៨៨ ៦៩១ ៦៩១១ | ០២៣ ៦៦៣ ៣០៣០ | vannaknssf@nssf.gov.kh |

# បញ្ជីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ
# បេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបថែទាំសុខភាព

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាមុយ | ទូរស័ព្ទទំនាក់ទំនង | ភ្នាក់ងារ ប.ស.ស | រាជធានី/ខេត្ត |
|---|---|---|---|---|---|
| ១ | មន្ទីរពេទ្យព្រះកុសុមៈ | 089 761 767 | 012 304 454 (ប្រធានគណនេយ្យ) | 017 378 456/ 069 858 806<br>012 846 504/ 086 509 015 | |
| ២ | មន្ទីរពេទ្យព្រះអង្គឌួង | 070 945 050 | 011 755 119 (ប្រធានគណនេយ្យ) | 010 264 017/ 093 915 210<br>031 222 1230/ 010 378 840 | |
| ៣ | មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | | 012 222 773 (ប្រធាន)<br>012 878 283 (អនុប្រធាន)<br>012 764 812 (អនុប្រធានគណនេយ្យ) | 095 991 859/ 086 611 566<br>015 507 520/ 069 646 039 | |
| ៤ | មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ | 699 | 077 559 987 (ប្រធាន)<br>012 939 500 )អនុប្រធាន<br>011 862 760 (ប្រ.គណនេយ្យ) | 011 788 011/ 098 890 607<br>070 885 507/ 010 252 590 | |
| ៥ | មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិនសែនសុខ | 095 866 606<br>011 884 302 (ប្រធាន) | 011 884 302 (ប្រធាន) | 086 245 454/ 096 378 1119<br>012 319 705/ 078 921 296 | |
| ៦ | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង | 017 722 065 | 012 853 013 (ប្រធាន) | 012 884 766/ 092 692 031<br>069 627 334/ 081 837 439 | |
| ៧ | មន្ទីរពេទ្យបង្អែកដង្កោ | 092 382 263<br>070 382 263 | 012 724 298 (អនុប្រធាន) | 077 233 556/ 015 217 317<br>016 600 477/ 012 588 076 | |
| ៨ | មន្ទីរពេទ្យបង្អែកមានជ័យ | 077 524 256 (ប្រធាន) | 077 524 256 (ប្រធាន) | 086 387 573/ 095 789 996<br>097 984 4938/ 010 202 066 | |
| ៩ | មន្ទីរពេទ្យបង្អែកសម្តេចឪ | 012 876 916 | 012 864 684 (ប្រធាន) | 078 668 897/ 081 377 790<br>092 891 986/ 069 328 095 | |
| ១០ | មន្ទីរពេទ្យបង្អែកព្រែកព្នៅ | 077 748 274 | 012 656 639 (ប្រធាន) | | |
| ១១ | មណ្ឌលសុខភាពសំរោងក្រោម | | 017 328 481 (ប្រធាន) | | |
| ១២ | មណ្ឌលសុខភាពសាមគ្គី | | 012 614 514 (ប្រធាន) | | |
| ១៣ | មណ្ឌលសុខភាពបឹងធំ | | 017 583 598 (ប្រធាន) | | ភ្នំពេញ |
| ១៤ | មណ្ឌលសុខភាពកំបូល | | 012 281 914 (ប្រធាន) | | |
| ១៥ | មណ្ឌលសុខភាពស្នោរ | | 012 753 889 (ប្រធាន) | | |
| ១៦ | មណ្ឌលសុខភាពអន្លង់ក្ងាន | | 017 866 002 (ប្រធាន) | | |
| ១៧ | មណ្ឌលសុខភាពក្រាំងធ្នង់ | | 015 797 922 (ប្រធាន) | | |
| ១៨ | មណ្ឌលសុខភាពភ្នំពេញថ្មី | | 012 306 449 (ប្រធាន) | | |
| ១៩ | មណ្ឌលសុខភាពឃ្មួញ | | 015 524 020 (ប្រធាន) | | |
| ២០ | មណ្ឌលសុខភាពទឹកថ្លា | | 012 927 052 (ប្រធាន) | | |
| ២១ | មណ្ឌលសុខភាពល្វេស | | 095 904 040 (ប្រធាន) | | |
| ២២ | មណ្ឌលសុខភាពព្រែកកំពឹស | 017 712 922 | 017 712 922 (ប្រធាន) | | |
| ២៣ | មណ្ឌលសុខភាពពងទឹក | | 012 867 416 (ប្រធាន) | | |
| ២៤ | មណ្ឌលសុខភាពព្រៃវែង | | 097 696 8990 (ប្រធាន) | | |
| ២៥ | មណ្ឌលសុខភាពចំការដូង | | 077 788 825 (ប្រធាន) | | |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាមុយ | ទូរស័ព្ទទំនាក់ទំនង | ភ្នាក់ងារ ប.ស.ស | រាជធានី/ខេត្ត |
|---|---|---|---|---|---|
| ២៦ | មណ្ឌលសុខភាពព្រៃស | | 078 789 822 ( ប្រធាន ) | | ភ្នំពេញ |
| ២៧ | មណ្ឌលសុខភាពជើងឯក | | 095 980 656 ( ប្រធាន ) | | |
| ២៨ | មជ្ឍមណ្ឌលសុខភាពទួលគោក | 012 244 471 | 011 833 339 ( ប្រធាន ) | | |
| ២៩ | មណ្ឌលសុខភាព ៧មករា | | 012 805 900 ( ប្រធាន ) | | |
| ៣០ | មណ្ឌលសុខភាពទួលស្វាយព្រៃ | | 011 219 922 ( ប្រធាន ) | | |
| ៣១ | មណ្ឌលសុខភាពដូនពេញ | 010 685 252 | 011 828 787 ( ប្រធាន ) | | |
| ៣២ | មណ្ឌលសុខភាពផ្សារដើមថ្កូវ | 011 415 507 | 098 222 243 ( ប្រធាន ) | | |
| ៣៣ | មណ្ឌលសុខភាពព្រែកថ្មី | | 012 202 270 ( ប្រធាន ) | | |
| ៣៤ | មណ្ឌលសុខភាពស្ទឹងមានជ័យ | | 012 839 162 ( ប្រធាន ) | | |
